គម្រោងវារីអគ្គិសនី ជាគម្រោងមួយដែលនឹងត្រូវសាងសង់នៅប៉ែកឦសាននៃប្រទេសកម្ពុជាយើង គឺស្ថិតនៅក្នុងខេត្តស្ទឹងត្រែងតែម្តង។ គម្រោងថាមពលផលិត៖ ៤០០មេហ្គាវ៉ាត់

- កំពស់៖ ៧៥ម៉ែត្រ
- ប្រវែង៖ ៦គីឡូម៉ែត្រ
- ទំហំផ្ទៃអាងទឹក៖ ៣៣ ៥៦០ហិកតា
- ចំណាយទុនសាងសង់៖ ៧៨១លានដុល្លាសហរដ្ឋអាមេរិច

### ❖ មូលហេតុនៃការសិក្សាស្រាវជ្រាវ

- គម្រោងនេះ មានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ
- ជាគម្រោងដែលទើបទទួលបានការអនុញ្ញាតអោយដំណើរការសាងសង់ជាផ្លូវការ
- ការសិក្សាពីការចូលរួមជាសាធារណៈរបស់ប្រជាជន តួនាទីនិងសកម្មភាពរបស់ស្ថាប័ន ដើម្បីធ្វើអោយការចូលរួមជាសាធារណៈមានភាពល្អប្រសើរ និងការផ្តល់សំណងនៃគម្រោងវារីអគ្គិសនីសេសានក្រោម២ មិនទាន់មានអ្នកសិក្សាច្រើននៅឡើយ

### ❖ គោលបំណងជាក់លាក់

- វិភាគពីតួនាទី របស់ស្ថាប័នក្នុងការចូលរួមចំនែកធ្វើឲ្យការចូលរួមជាសាធារណៈនៅថ្នាក់មូលដ្ឋាន នៃគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីសេសានក្រោម២ បានល្អប្រសើរ
- វិភាគពីការចូលរួមជាសាធារណៈរបស់ប្រជាជននៅថ្នាក់មូលដ្ឋាន នៃគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីសេសានក្រោម២ មុនពេលដំណើរការសាងសង់
- សិក្សាពីសំណងផលប៉ះពាល់ និងការផ្លាស់ទីលំនៅថ្មីនៃគម្រោងអភិវឌ្ឍវារីអគ្គិសនីសេសានក្រោម២

## II. វិធីសាស្រ្តសិក្សាស្រាវជ្រាវ

### ❖ ការជ្រើសរើសទីតាំងសិក្សា

- ភូមិស្រែគរ១ ភូមិស្រែស្រណុក និងភូមិក្បាលរមាស ស្ថិតនៅតាមដងទន្លេសេសាន
- ប្រជាជនមូលដ្ឋានរស់នៅដោយពឹងផ្អែកលើធនធានធម្មជាតិ(ធនធានព្រៃឈើ និងមិនមែនធនធានព្រៃឈើ) ការធ្វើកសិកម្ម និងការនេសាទជាដើម

## III. លទ្ធផល និងការពិភាក្សា

❖ **តួនាទី និងទំនួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធក្នុងថ្នាក់មូលដ្ឋាន**

- មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល៖ ជាអ្នកចេញគោលនយោបាយ ត្រួតពិនិត្យលើការវាយតំលៃលើគម្រោង និងការចុះសិក្សាពីទីតាំងលំនៅដ្ឋានថ្មី។
- មន្ទីរធនធានទឹក និងឧតុនិយម៖ រៀបចំប្រព័ន្ធស្រោចស្រពវិស័យកសិកម្ម នៅពេលទទួលបានការអនុញ្ញាតពីម្ចាស់គម្រោង
- មន្ទីរបរិស្ថាន៖ គ្រប់គ្រងទៅលើច្បាប់ការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ និងត្រួតពិនិត្យពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (EIA) របស់ក្រុមហ៊ុន។
- សាលាស្រុកសេសាន៖ ជាអ្នកសម្របសម្រួល និងលើសកម្មភាពអនុវត្តន៍មួយចំនួននៃគម្រោង
- អាជ្ញាធរភូមិឃុំ៖ មានតួនាទីជាអ្នកតំណាង អ្នកផ្សព្វផ្សាយ និងជាអ្នកសម្របសម្រួលរបស់ប្រជាជនសហគមន៍
- ស្ថាប័នក្រៅរដ្ឋាភិបាល៖ ជាអ្នកសម្របសម្រួល, ជាអ្នកផ្តល់ព័ត៌មាន និងជាអ្នកបង្រៀននូវជំនាញវិជ្ជាជីវៈថ្មីៗដល់ប្រជាពលរដ្ឋមូលដ្ឋាន

❖ **ការចូលរួមជាសាធារណៈ**

- ថ្នាក់មូលដ្ឋាន ៖ គ្រួសារប្រជាជនរងប៉ះពាល់ទាំងអស់ អាជ្ញាធរភូមិឃុំ មន្ត្រីស្ថាប័នថ្នាក់ខេត្ត ស្រុក តំណាងក្រុមហ៊ុន
- ថ្នាក់ស្រុក ៖ តំណាងប្រជាជនរងប៉ះពាល់ អាជ្ញាធរភូមិឃុំ មន្ត្រីស្ថាប័នថ្នាក់ខេត្ត ស្រុក និងតំណាងក្រុមហ៊ុន
- ថ្នាក់ខេត្ត ៖ តំណាងប្រជាជនរងប៉ះពាល់ អាជ្ញាធរភូមិឃុំ មន្ត្រីស្ថាប័នថ្នាក់ខេត្ត ស្រុក និងតំណាងក្រុមហ៊ុន
- ថ្នាក់ជាតិ ៖ តំណាងប្រជាជនរងប៉ះពាល់ មន្ត្រីស្ថាប័នថ្នាក់ខេត្ត ស្រុក តំណាងក្រុមហ៊ុន និងតំណាងអង្គការតិចតួច
- ការចូលរួមជាសាធារណៈនៃ គម្រោងអភិវឌ្ឍន៍វារីអគ្គិសនីសេសានក្រោម២
  - ការចូលរួមជាសាធារណៈបានធ្វើឡើងនៅអំឡុងពេលធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានតំបូង
  - ការចូលរួមជាសាធារណៈត្រូវបានធ្វើឡើង ២ដង
    - ✓ នៅឃុំទទួលរងគ្រោះនីមួយ (ប្រជាជនមូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធរថ្នាក់ខេត្ត ក្រុមវាយតំលៃហេតុប៉ះពាល់បរិស្ថានតំបូង អ្នកដំណាំងក្រុមហ៊ុន)
    - ✓ នៅខេត្តស្ទឹងត្រែង (ប្រជាជនមូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធរថ្នាក់ខេត្ត ក្រុមវាយតំលៃហេតុប៉ះពាល់បរិស្ថានតំបូង អ្នកដំណាំងក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាល)

❖ **យន្តការនៃការចូលរួមជាសាធារណៈ**

- ភាពខ្វះចន្លោះក្នុងការអនុវត្តនូវយន្តការចូលរួមជាសាធារណៈ

- ធ្វើការផ្សព្វផ្សាយព័ត៌មាន និងលទ្ធផលនៃ ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃគម្រោង
- ស្ទាបស្ទង់មតិរបស់ប្រជាជន
- និតិវិធីក្នុងការជ្រើសរើសអ្នកចូលរួមមិនទាន់មានប្រសិទ្ធភាព

• ការមិនយកចិត្តទុកដាក់ស្តាប់របស់ប្រជាជនមូលដ្ឋាន ទៅលើការបកស្រាយរបស់អ្នកធ្វើបទបង្ហាញ

❖ **ប្រសិទ្ធភាពនៃការចូលរួមជាសាធារណៈ**

• ការព្រួយបារម្ភរបស់ប្រជាជនមូលដ្ឋានមិនត្រូវបានលើកឡើងច្រើន
• ការចូលរួមជាសាធារណៈមិនសូវផ្តល់នូវផលប្រយោជន៍ច្រើនសំរាប់ប្រជាជនមូលដ្ឋាន
• បញ្ហាដែលអាចកើតមានឡើងដែលបានបង្ហាញមានតែបញ្ហាផ្លាស់ប្តូរទីតាំងភាគច្រើន
• ចំនេះដឹងមិនសូវផ្តល់ទូលំទូលាយ

❖ **ស្តង់ដានៃការអនុវត្តន៍ការចូលរួមជាសាធារណៈ**

១. និយាយពីសកម្មភាពនៃការសម្រេចចិត្តលើផលប៉ះពាល់ការរស់នៅរបស់ប្រជាជន
២. មានការរួមបញ្ចូលទាំងកិច្ចសន្យាដែលមានឥទ្ធិពលលើការសម្រេចចិត្ត
៣. បង្ហាញពីចំណាប់អារម្មណ៍ និងតម្រូវការអ្នកចូលរួមទាំងអស់
៤.
ដំណើរការសម្របសម្រួលនិងស្វែងរកមនុស្សដែលមានសក្តានុពលទៅលើការសម្រេចចិត្តចំពោះគម្រោង
៥. កំណត់ពីរចនាសម្ព័ន្ធនៃដំណើរការចូលរួមជាសាធារណៈ
៦. ផ្តល់អោយនូវព័តមានដែលប្រជាជនចង់ដឹងដើម្បីអោយការចូលរួមមានអត្ថ ប្រយោជន៍
៧. ដំណើរការនៃការចូលរួមជាសាធារណៈដែលការចូលរួមមានឥទ្ធិពលលើការ

• ការចូលរួមជាសាធារណៈនៃគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីសេសានក្រោម២ មិនបានស្របតាមស្តង់ដារដែលបានរៀបចំ ឡើងដោយ IAPP(International Association for Public Participation)
    - អំណាចប្រជាជនមិនសូវបានលើកកម្ពស់
    - ការចូលរួមរបស់ប្រជាជនមិនមានឥទ្ធិពលក្នុងការសម្រេចចិត្ត
    - ពេលវេលាក្នុងការរៀបចំការចូលរួមជាសាធារណៈខ្លី
    - គុណសម្បត្តិនៃគម្រោងបានលើកឡើងច្រើន

❖ **ព័ត៌មាន និងជម្រើសនៃការផ្តល់សំណង**

• ជម្រើសក្នុងការផ្តល់ និងទទួលសំណងពីគម្រោងអភិវឌ្ឍន៍មាន២ គឺ
    - សំណងជាលុយ៖ ទាំងផ្ទះ ដីភូមិ ដីកសិកម្ម ដំណាំគិតជាលុយទាំងអស់
    - សំណងជាទ្រព្យសម្បត្តិ៖ មានផ្តល់ផ្ទះទំហំ ៦៤ ម៉ែតការ៉េ (សម្រាប់មនុស្ស៨នាក់) ដីភូមិ០,៥ហិចតា ដីកសិកម្ម៥ហិចតា និងដំណាំគិតជាលុយ

- ❖ ទស្សនៈរបស់ប្រជាជនលើផែនការនៃបែងចែកផលចំនេញ
- ការដឹកជញ្ជូន
- ប្រជាជនទទួលបានសេវាសាធារណៈ
- ដីស្រែ ចំការ និងដីផ្ទះ
- ប្រាក់ចំណូល

- ❖ **ទីតាំងលំនៅឋានថ្មី**
- ចំពោះភូមិស្រែស្រណុក មានទីតាំង២ គឺPK479 - PK480 និង PK495 - PK503 (នៅតាមផ្លូវជាតិ៧៨)
- ចំនែកឯភូមិស្រែគរ១ ក៏មាន២ទីតាំងដែរគឺ ចំងាយពីភូមិចាស់១៥គីឡូម៉ែត និងនៅភូមិញ៉ឺន

## IV. សន្និដ្ឋាន

- ទោះបីជាមានការចូលរួមជាសាធារណៈក៏ដោយ ប្រជាពលរដ្ឋមូលដ្ឋានមិនសូវទទួលបានផលប្រយោជន៍នេះទេ និងមិនសូវមានប្រសិទ្ធិភាបប៉ុន្មាននោះទេ ពីព្រោះប្រជាជនពុំសូវទទួលបានព័ត៌មានច្បាស់លាស់ និងធ្វើការបញ្ចេញយោបល់ច្រើននៅពេលធ្វើការចូលរួមជាសាធារណៈ។
- រីឯផែនការក្នុងការផ្តល់សំណងវិញ ហាក់បីដូចជាមានលក្ខណៈល្អប្រសើរ( គោលនយោបាយច្បាស់ និង តាមទីផ្សារ)
- សំណង (ប្រាក់ និងជាទ្រព្យសម្បត្តិ) និងផលចំនេញ

- ❖ អនុសាសន៍
- រៀបចំសិក្ខាសាលាឲ្យបានច្រើន ស្តីពីការអភវឌ្ឍវារីអគ្គិសនី នៅតំបន់ជនបទដែលនៅតាមដងទន្លេ
- ក្រុមហ៊ុនវិនិយោគគួរតែមានគោលការណ៍ ក្នុងការផ្តល់ព័ត៌មានពីគម្រោងអភិវឌ្ឍន៍ វារីអគ្គិសនីឲ្យបានគ្រប់ផ្នែក និងច្បាស់លាស់មុនពេលអនុវត្តគម្រោង
- ក្រុមហ៊ុនវិនិយោគ គួរតែពង្រឹងក្នុងការរៀបចំ និងការអនុវត្តផែនការក្នុងការចូលរួមជាសាធារណៈ
- ក្រុមហ៊ុនវិនិយោគ ត្រូវបង្កើនសម្លេងរបស់ប្រជាពលរដ្ឋ ដើម្បីឲ្យពួគគាត់មានលទ្ធភាពទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍ។
- ក្រុមហ៊ុនវិនិយោគ គួរតែផ្តល់ឯកសារដែលទាក់ទងនិងគម្រោងអភិវឌ្ឍន៍ជាភាសាជាតិ (ភាសាខ្មែរ)
- ប្រជាជនជនមូលដ្ឋាន គួរតែយកចិត្តទុកដាក់ទទួលយកនូវព័ត៌មានទាំងអស់ដែលអាច ជះឥទ្ធិពលលើកំរិតជីវៈភាពរបស់ពួគគាត់ អំឡុងពេលចូលរួមជាសាធារណៈ

## Appendix Four: Key Results of Community-based Research by Ms. Nen Sokhet, Community Researcher (In Khmer)

### ការសិក្សាស្រាវជ្រាវដោយសហគមន៍ស្តីពីការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២

**គោលបំណងនៃការស្រាវជ្រាវ**

ដើម្បីស្វែងរកការពិត ពីស្ថានភាពបច្ចុប្បន្ន ស្តីពីការកាប់ឈើសំអាតផ្ទៃអាងស្តុកទឹក ផែនការតាំងទីលំនៅថ្មី និងផែនការសំណងចំពោះប្រជាពលរដ្ឋ ដែលនឹងរងផលប៉ះពាល់ដោយសារ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម២។

**សំណួរស្រាវជ្រាវ**

គឺបានផ្តោតសំខាន់ទៅលើការទទួលបានព័ត៌មានរបស់សហគមន៍ ដែលកំពុងរស់នៅក្នុងតំបន់គំរោងទំនប់វារីអគ្គិសនីសេសានក្រោម២។ តើប្រជាពលរដ្ឋទទួលបានព័ត៌មានកំរិតណា ចំពោះសកម្មភាពសំអាតផ្ទៃអាងស្តុកទឹក? តើពួកគាត់បានដឹងពីកន្លែងតាំងទីលំនៅថ្មីហើយឬនៅ? តើមានការផ្សព្វផ្សាយជាសាធារណ:ហើយឬនៅ ពាក់ព័ន្ធនឹងគោលការណ៍សំណងដែលសភាជាតិបានអនុមតិរួចហើយកាលពីដើមឆ្នាំ២០១៣?

**វិធីសាស្ត្រនៃការស្រាវជ្រាវ**

ស្រាវជ្រាវតាមឯកសារដែលមានស្រាប់ មានដូចជា របាយការណ៍ស្រាវជ្រាវរបស់វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) របាយការណ៍សិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងតាមរយ:គេហទំព័រ។

- ចុះប្រមូលព័ត៌មានជាមួយសហគមន៍ដែលត្រូវទទួលរងផលប៉ះពាល់ដោយសារគម្រោងទាំងផ្នែកខាងក្រោមទំនប់ និងផ្នែកខាងលើទំនប់។
- សិក្សាពីផែនទីភូមិ ដើម្បីចង់ដឹងពីទីតាំងថ្មីដែលត្រូវបានស្នើសុំដោយអ្នកភូមិ។

**ទំហំនៃការស្រាវជ្រាវ**

**ការសិក្សាស្រាវជ្រាវនេះ គឺបានជ្រើសរើសភូមិចំនួន៥៖**

- ភូមិស្រែគរ១
- ភូមិស្រែគរ២
- ភូមិក្បាលរមាស
- ភូមិស្រែស្រណុក
- ភូមិភ្លុក

យុំចំនួន៣ រួមមាន៖

- ឃុំភ្លុក
- ឃុំស្រែគរ
- ឃុំក្បាលរមាស(ស្ថិតក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង)

**លទ្ធផលរំពឹងទុក**

ការសិក្សានេះ

និងក្លាយជាឧបករណ៍មួយសម្រាប់សហគមន៍ដែលរងផលប៉ះពាល់ដោយសារទំនប់វារីអគ្គិសនីសេសានក្រោម២ បានសិក្សាស្រាវជ្រាវដោយខ្លួនឯង ក្នុងគោលបំណងដើម្បីបង្ហាញ អំពីការផ្តល់សិទ្ធិអំណាចដល់សហគមន៍ និងធ្វើឲ្យពួកគាត់មានទំនុកចិត្តក្នុងការតស៊ូមតិ ពីកំរិតមូលដ្ឋានទៅដល់ថ្នាក់ជាតិ ដោយផ្អែកលើលទ្ធផលស្រាវជ្រាវរបស់ពួកគាត់ផ្ទាល់ និងការពិភាក្សាជាមួយរដ្ឋាភិបាលកម្ពុជា។

**សង្ខេបប្រវត្តិគំរោង**

ទំនប់វារីអគ្គិសនីសេសានក្រោម២ ជាគម្រោងខ្នាតធំដំបូងបង្អស់មួយ ដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា។ ទំនប់នេះមានទីតាំងបិតនៅក្នុងភូមិភ្លុក ឃុំភ្លុក ស្រុកសេសាន ខេត្តស្ទឹងត្រែង មានចម្ងាយប្រហែល១,៥គីឡូម៉ែត្រ ខាងក្រោមចំនុចប្រសព្វទន្លេសេសាន និងទន្លេស្រែពក។ ទំនប់នេះមានសមត្ថភាពផលិតថាមពលអគ្គិសនីបាន៤០០មេហ្គាវ៉ាត់ ឬ ជាមធ្យម ១៩៥៣,៩លានគីឡូវ៉ាត់ម៉ោងក្នុង១ឆ្នាំ។ គម្រោងនេះ តំរូវឲ្យប្រជាពលរដ្ឋចំនួន៥ភូមិត្រូវធ្វើការផ្លាស់ប្តូរទីលំនៅថ្មី ដោយសារភូមិទាំងនោះ បិតនៅក្នុងផ្ទៃនៃអាងស្តុកទឹកចំណុះ ១,៧៩លានម៉ែត្រគូប លើផ្ទៃដីព្រៃសរុប ៣៦ពាន់ហិកតា។ ទំនប់នេះ ត្រូវបានវិនិយោគជាលក្ខណៈ BOT (សាងសង់ ប្រតិបត្តិការ ផ្ទេរ)។

**ការរកឃើញ**

**១. ការកាប់ឈើសំអាតផ្ទៃអាងស្តុកទឹក**

- ការកាប់ឈើសំអាតផ្ទៃអាងស្តុកទឹកត្រូវបានចាប់អនុវត្តនៅអឡុងខែមេសា ឆ្នាំ២០១៣ ដោយក្រុមហ៊ុនមួយឈ្មោះអាង អែន អាសូស៊ីអេស៊ិន ឡយ័រ ខូអិលធីឌី (ANG & Association Lawyer Co.,ltd)
- ប្រជាពលរដ្ឋដែលរស់នៅផ្នែកខាងក្រោមនៃទំនប់ គឺមិនបានទទួលព័ត៌មានស្តីពីការកាប់ឈើសំអាតផ្ទៃអាងទេ។
- ប្រជាពលរដ្ឋដែលកំពុងនៅក្នុងអាងស្តុកទឹក ភាគច្រើនមិនបានដឹងពីផែនការសំអាតអាងស្តុកទឹក ពួកគាត់គ្រាន់តែបានដឹងពីព័ត៌មានស្តីពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីក្នុងតំបន់ដែល ពួកគាត់កំពុងរស់នៅតែប៉ុណ្ណោះ។
- ប្រជាពលរដ្ឋមិនបានទទួលព័ត៌មានច្បាស់លាស់ពីទំហំពិតប្រាកដរបស់អាងស្តុកទឹក។
- ការដឹកជញ្ជូនឈើរបស់ក្រុមហ៊ុន បានធ្វើឲ្យផ្លូវ ស្ពានចូលភូមិខូចខាតយ៉ាងខ្លាំង។
- អ្នកភូមិបានប្រាប់ឲ្យដឹងថា មានការកាប់ឈើយ៉ាងអនាធិប្បតេយ្យ នៅខាងក្រៅអាងស្តុកទឹក រួចហើយដឹកជញ្ជូនចូលមកក្នុងតំបន់អាងស្តុកទឹក។
- ការអនុវត្តន៍សកម្មភាពរបស់ក្រុមហ៊ុន គឺធ្វើឡើងដោយមានការលាក់លៀម និងព្យាយាមបិទបាំងព័ត៌មាន។
- រដ្ឋាភិបាលបានចេញ ស.ជ.ណ ដើម្បីឲ្យក្រុមហ៊ុនផ្អាកសកម្មភាពកាប់ឈើសំអាតអាងស្តុកទឹក ក្នុងខែតុលា ឆ្នាំ២០១៣ ដើម្បីឲ្យមន្ត្រីបច្ចេកទេសចុះវាស់វែង និងកំណត់ព្រំប្រទល់អាងស្តុកទឹកឲ្យបានច្បាស់លាស់។

➢ ប៉ុន្តែ ទោះបីជាមាន ស.ជ.ណ ក៏ដោយ ក្រុមហ៊ុនមិនបានផ្អាកសកម្មភាពរបស់ខ្លួនទេ ដោយបានប្តូររូបភាពពីការអនុវត្តន៍ផ្ទាល់ មកជាបំផុសឲ្យប្រជាជនកាប់ឈើលក់ឲ្យក្រុមហ៊ុន។

**២. ផែនការតាំងទីលំនៅថ្មី**

➢ ប្រជាពលរដ្ឋទាំង៩ភូមិ ដែលត្រូវផ្លាស់ប្តូរទីលំនៅថ្មី រហូតមកដល់ពេលនេះ គឺនៅមិនដឹងថាត្រូវទៅកន្លែងណាឲ្យពិតប្រាកដនោះទេ។

➢ មិនមានការផ្សព្វផ្សាយជាសាធារណៈ អំពីផែនការតាំងទីលំនៅថ្មីសម្រាប់ប្រជាពលរដ្ឋដែលនិងត្រូវធ្វើការផ្លាស់ប្តូរ។

➢ ជម្រើសរបស់ប្រជាពលរដ្ឋដែលបានស្នើសុំ សម្រាប់កន្លែងតាំងទីលំនៅថ្មី ក៏មិនមានការឆ្លើយតបពីសំណាក់រាជ រដ្ឋាភិបាល និងក្រុមហ៊ុន។

➢ ប្រជាពលរដ្ឋក្នុងភូមិក្របីជ្រុំ និងខ្សាច់ថ្មី ហាក់នៅស្រពិចស្រពិល ថាតើភូមិរបស់ពួកគាត់និងធ្វើការផ្លាស់ប្តូរទីតាំងឬអត់ បើទោះជាការផ្សព្វផ្សាយពីដំបូងរបស់ក្រុមហ៊ុនថា ភូមិរបស់ពួកគាត់នឹងមិនលិចទឹកនោះទេ។

➢ ចំណែកប្រជាពលរដ្ឋដែលរស់នៅផ្នែកខាងក្រោមនៃទំនប់គឺ មិនមានផែនការផ្លាស់ប្តូរទីលំនៅទេ ប៉ុន្តែពួកគាត់បានប្រាប់ឲ្យដឹងថា ភាគីក្រុមហ៊ុនបានផ្សព្វផ្សាយដល់ពួកគាត់ ពីការជម្លៀសបណ្តោះអាសន្នក្នុងពេលដំណើរការសាងសង់ (បំផ្ទុះថ្មគ្រិះទំនប់) មានគ្រួសារមួយចំនួនត្រូវជម្លៀសចេញពីភូមិ ដើម្បីសុវត្ថិភាព ហើយក្រុមហ៊ុននិងរៀបចំទីកន្លែងសុវត្ថិភាពសម្រាប់អ្នកភូមិ និងចេញថ្លៃសំណងចំពោះការខូចខាតជាក់ស្តែង។

**៣. ផែនការ និង គោលការណ៍សំណង**

➢ រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអនុមតិច្បាប់ និង គោលការណ៍សំណងចំពោះគំរោង ទំនប់វារីអគ្គិសនី សេសានក្រោម២ នៅដើមឆ្នាំ ២០១៣ ប៉ុន្តែប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ នៅមិនទាន់ទទួលបានការផ្សព្វផ្សាយ លំអិតណាមួយស្តីពីគោលការណ៍សំណងដែលពួកគាត់និងទទួលបាននៅឡើយទេ។

➢ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ទាំង៩ភូមិ គ្រាន់តែបានដឹងថា គេនិងសង់ផ្ទះឲ្យ១ខ្នង (ទំហំផ្ទះអាស្រ័យលើចំនួនសមាជិកគ្រួសារ) ដីភូមិ ៥០ម x ១០០ម ដីស្រែ ៥ហិកតា ដីចំការ ១ហិកតា ប៉ុន្តែពួកគាត់អត់ទាន់ដឹងថានៅទីកន្លែងណា និងពេលណា ត្រូវផ្លាស់ប្តូរពិតប្រាកដនោះទេ។

➢ ប្រជាពលរដ្ឋក្នុងភូមិក្របីជ្រុំ និងខ្សាច់ថ្មី មានការព្រួយបារម្ភជាខ្លាំងចំពោះគោលការណ៍សំណង ពីព្រោះពួកគាត់មិនទាន់ដឹងច្បាស់ថា តើពួកគាត់មានឈ្មោះនៅក្នុងបញ្ជីប្រជាជនដែលនិងត្រូវទទួលបានសំណងដែរឬអត់

**ការសន្និដ្ឋាន**

គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម២ គឺជាគម្រោងខ្នាតធំទី១ ក្នុងប្រទេសកម្ពុជា ជាគម្រោងមួយពិតប្រាកដ មានផែនការច្បាស់លាស់ និងមានដំណើរការឆ្ពោះទៅមុខគួឲ្យកត់សំគាល់ចាប់តាំងពីឆ្នាំ២០០៧។ គម្រោងនេះបានធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានបឋមនៅឆ្នាំ ២០០៨ និង សិក្សាវាយតំលៃពេញលេញក្នុងឆ្នាំ២០០៩ ប៉ុន្តែអ្វីដែលជាការកត់សំគាល់នោះគឺ

- ក្រុមហ៊ុនដែលទទួលបានសិទ្ធិក្នុងការកាប់ឈើសំអាតផ្ទៃអាងស្តុកទឹក ព្យាយាមបិទបាំងព័ត៌មានចំពោះសកម្មភាពរបស់ខ្លួន ។
- មានការប្រមូលទិញឈើយ៉ាងអនាធិប្បតេយ្យពីខាងក្រៅនៃតំបន់អាងស្តុកទឹក។
- មានការរារាំងពីសំណាក់បុគ្គលិកក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋាន (ប៉ូលីសប៉ុស្តិ៍) ក្នុងការរៀបចំការប្រជុំពិគ្រោះយោបល់ជាមួយសហគមន៍ដែលទទួលរងផលប៉ះពាល់ ជាមួយមន្ត្រីអង្គការសង្គមស៊ីវិល។
- ផែនការ, ទីកន្លែងតាំងទីលំនៅថ្មី និងគោលការណ៍សំណងនៅមិនទាន់បានផ្សព្វផ្សាយជាសាធារណ:ទៅដល់ប្រជាពលរដ្ឋក្នុងតំបន់អនុវត្តគម្រោង។
- រាល់សំណូមពរ និងការស្នើសុំរបស់អ្នកភូមិ នៅមិនទាន់មានការឆ្លើយតប ពីសំណាក់រាជរដ្ឋាភិបាល ក៏ដូចជា ភាគីក្រុមហ៊ុនវិនិយោគ។
- **ដូច្នេះ តម្លាភាព, គណនេយ្យភាព, សេរីភាពក្នុងការទទួលបានព័ត៌មាន និងការចូលរួមសម្រេចចិត្តរបស់សហគមន៍ក្នុងការអភិវឌ្ឍន៍ គឺពិតជាមាន សារៈសំខាន់ណាស់ ដើម្បីធ្វើឲ្យការអភិវឌ្ឍន៍មួយ មាននិរន្តភាព។**

## សំណូមពរ

- ផ្សព្វផ្សាយពីច្បាប់ និងគោលការណ៍ផ្សេងៗជាសាធារណ:
- ការអនុវត្តសកម្មភាពរបស់ក្រុមហ៊ុនត្រូវធ្វើឡើងដោយបើកចំហដើម្បីងាយស្រួលសហគមន៍ចូលរួមតាមដានត្រួតពិនិត្យ។
- ក្រុមហ៊ុនត្រូវអនុវត្ត ទៅតាមច្បាប់ដែលបានចែង និងទាន់ពេលវេលា។
- រៀបចំវេទិកាសាធារណ:ដើម្បីឲ្យសហគមន៍មានឪកាសសម្តែងមតិយោបល់របស់ពួកគាត់។
- ក្រុមហ៊ុនត្រូវគោរពទៅលើប្រពៃណី វប្បធម៌របស់សហគមន៍។

## បច្ចុប្បន្ន ២០១៤

- សហគមន៍ក្នុងតំបន់គម្រោងបដិសេធចំពោះការតាំងទីលំនៅថ្មី ពិសេសនៅភូមិក្បាលរមាស និងភូមិស្រែគរ ១ និងស្រែគរ ២ ដោយនិយាយថា "សូមលុបចោលគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២
- សហគមន៍ភូមិក្បាលរមាស និងស្រែគរ ១ និងស្រែគរ២បានរៀបចំសេចក្តីថ្លែងការណ៍បើកចំហរ និងដាក់ជូនគណ:ដោះស្រាយផលប៉ះពាល់នៅថ្នាក់ខេត្តស្ទឹងត្រែង ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ដើម្បីបដិសេធការតាំងទីលំនៅថ្មី
- សហគមន៍បានប្រមើមើលឃើញថា គម្រោងនេះ នឹងធ្វើឲ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ជីវភាពសហគមន៍ សង្គម និងបរិស្ថាន ជាហេតុធ្វើឲ្យសហគមន៍មានគោលជំហរតែមួយ គឺមិនត្រូវការគម្រោងនេះ និងសុំឲ្យរដ្ឋាភិបាលលុបចោល គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២

## Appendix Five: Current Status of Lower Sesan 2 Hydro Dam Development by Mr. Meach Mean (In Khmer)

### បច្ចុប្បន្នភាពនៃគំរោងទំនប់វារីអគ្គិសនីសេសានក្រោម២

**ព្រឹត្តិការណ៍សំខាន់ៗ**

- ខែមិថុនា ឆ្នាំ២០០៧៖ អនុស្សរណៈយោគយល់គ្នាមួយ (MOU) ត្រូវបានចុះហត្ថលេខារវាងអគ្គិសនី  វៀតណាម (EVN) និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនៃរដ្ឋាភិបាលកម្ពុជា ឲ្យក្រុមហ៊ុនអគ្គិសនីវៀតណាមធ្វើការសិក្សាពីលទ្ធភាពនៃការសាងសង់ទំនប់។
- ឆ្នាំ២០០៨ -២០០៩៖ ករណីសិក្សាពីលទ្ធភាពនៃការសាងសង់ទំនប់ត្រូវបានធ្វើឡើងដោយសាខាក្រុមហ៊ុនអគ្គិសនីវៀតណាម គឺភីអ៊ីស៊ីស៊ីមួយ (PECC1)
- ខែមករា ដល់ខែមិថុនា ឆ្នាំ២០០៨៖ ការសិក្សាពីហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវបានធ្វើឡើងដោយទីប្រឹក្សាកម្ពុជា(KCC)។
- ខែមិថុនា ឆ្នាំ២០១០៖ របាយការណ៍សិក្សាហេតុប៉ះពាល់បរិស្ថានរបស់គម្រោងត្រូវបានអនុម័ត។
- ខែមេសា ឆ្នាំ២០០១៖ ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីកម្ពុជា វៀតណាមដែលមានភាគហ៊ុនពីក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប៤៩% និងអគ្គិសនីវៀតណាមអន្តរជាតិ (EVNI)៥១% ត្រូវបង្កើតនិងទទួលស្គាល់ថា ជាអ្នកអភិវឌ្ឍទំនប់វារីអគ្គិសនីមួយនេះ។ ក្រោយមកបានចុះបញ្ជីជាផ្លូវការថា ក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម២ ខូអិលធីឌី(Hydro Power Lower Sesan 2 Co. ltd.) ក្នុងឆ្នាំ២០០១១ ដោយក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប។
- ខែវិច្ឆិកា ឆ្នាំ២០១២៖ ទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃរាជ  រដ្ឋាភិបាលកម្ពុជា។ កិច្ចព្រមព្រៀងសាងសង់ត្រូវបានចុះហត្ថលេខារវាងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប និងក្រុមហ៊ុនហាដ្រូឡានឆាងអ៊ិនធើណាសិនណាល់អ៊ិននើជី(Hydrolancang Internal Energy)។
- ខែកុម្ភៈ ឆ្នាំ២០១៣៖ ច្បាប់របស់រដ្ឋាភិបាលកម្ពុជាអំពីការទូទាត់សំណងលើគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ។
- ខែមីនា ឆ្នាំ២០១៣៖ កាសែតសារព័ត៌មានក្នុងស្រុកមួយបានចេញផ្សាយថា អាង &អាសូស៊ីអេសិន ឡោយើ ខូអិលធីឌី (Ang & Associate Lawer Co. ltd.) គឺជាក្រុមហ៊ុនដែលជាកម្មសិទ្ធិរបស់អ្នកឧកញ្ញាគិតម៉េង និងដែលបានកំពុងតែសំអាតផ្ទៃអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនី។
- ខែមករាឆ្នាំ 2014៖ បទបញ្ញានិងនីតិវិធីច្បាប់សម្រាប់ដោះស្រាយគោលនយោបាយសំណង និងការតាំងទីលំនៅថ្មីត្រូវបានអនុម័តដោយក្រសួងរ៉ែ និងថាមពល

(ពីមុនគឺក្រសួងឧស្សាហកម្ម រ៉ែ និថាមពល ប្តូរមកជាក្រសួង រ៉ែ និងថាមពល) ។ គោលនយោបាយដំណោះស្រាយសំណងសម្រាប់ផលប៉ះពាល់នៃគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានរៀបចំដោយក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម២ អិលធីឌី។

-
- ខែកុម្ភៈឆ្នាំ 2014៖ ការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២បានចាប់ផ្តើម។
- ខែមិនាឆ្នាំ 2014៖ គណៈកម្មាធិការសម្រាប់អនុវត្តន៍ការដោះស្រាយផលប៉ះពាល់នៃទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានបង្កើតឡើង និងអនុម័តដោយអភិបាលខេត្តស្ទឹងត្រែង។

**កំរិតថ្នាក់ជាតិ**

**ការកែគំរូប្លង់ថ្មីរបស់ទំនប់សេសានក្រោម២**

ថ្មីៗនេះយើងបានឮថាមានរបាយការណ៍ថ្មីមួយ ដែលបានធ្វើបច្ចុប្បន្នភាពនិងបានកែប្រែនៃគំរូប្លង់របស់ទំនប់វារីអគ្គិសនីសេសានក្រោម២សាជាថ្មី ។ ហើយគំរូប្លង់ទំនប់ថ្មីនោះ វាអាចធ្វើឲ្យមានប្រលោះលំហូរចេញបានងាយស្រួលរបស់កំណាក់ រីល្បប់ភក់ ដែលវាអាចជាការល្អប្រសើរជាងគំរូប្លង់ចាស់ ដែលរចនាឡើងបែបរាំងខ្ទប់នៃកំណាក់និងល្បប់ភួក។ រួចហើយគំរូប្លង់ថ្មីនោះទៀតសោធក៏ត្រូវបានកាត់បន្ថយផងដែរនូវកំពស់របស់ទំនប់ប្រមាណជា១០ម៉ែត្រផងដែរ។ ហើយវាអាចកាត់បន្ថយបាននូវហេតុប៉ះពាល់ជាអវិជ្ជមានបានយ៉ាងច្រើនចំពោះបរិស្ថានធម្មជាតិក៏ដូចជាបរិស្ថានសង្គម គឺវាអាចបញ្ជាសបាននូវការរុះរើតាំងទីលំនៅសាជាថ្មីរបស់អ្នកស្រុកនៅក្នុងតំបន់គំរោងបានមួយចំនួនទៀតផង។

**សំនួរ សួរថា:**

១.ហេតុអ្វីបានជារដ្ឋាភិបាលមិនយកនូវគំរូប្លង់ថ្មីនោះមកអនុវត្ត និងផ្សព្វផ្សាយជាសាធារណៈ?

ជាក់ស្តែងនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយកាលពីថ្ងៃទី៨ខែ១២ឆ្នាំ២០១៣ នៅភូមិស្រែគរ១ មានអ្នកចូលរួមប្រជុំប្រមាណ៨០ ក្នុងនោះស្ត្រីជា៥០នាក់ ក្នុងចំណោម ប្រជាជនសរុប២៥៦គ្រួសារក្នុងភូមិ គឺមានន័យថាអាចស្មើនឹងប្រមាណ៣០%តែប៉ុណ្ណោះ។

ជាលទ្ធផលនៃកិច្ចប្រជុំផ្សព្វផ្សាយនោះគឺមានតែប្រជាជនចំនួន៩នាក់ប៉ុណ្ណោះ ដែលបានលើកដៃទទួលយកគោលនយោបាយសំណង តាមការកំណត់ដោយឯកសារសំណង ក្នុងចំណោមអ្នកចូលរួម៨០នាក់ ម្យ៉ាងទៀតអ្នកដែលលើកដៃទទួលយកតាមគោលការណ៍នោះគឺសុទ្ធតែបុរសៗទៀតផង។

**សំណូមពរ:**

១. សំណូមពរសុំឲ្យផ្អាករាល់សកម្មភាពដែលបំរើឲ្យការសាងសង់ទំនប់សេសានក្រោម២នេះមួយរយៈរងចាំការព្រមព្រាងគ្នាជាមុនសិន

២. សូមឲ្យមានការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានសារថ្មី ដោយមានចូលរួមពីគ្រប់ភាគីពាក់ពន្ធ័ ជាពិសេសគឺសហគមន៍ដែលនឹងរងគ្រោះដោយសារគំរោង។

## លទ្ធផលប្រៀបធៀបរវាងគំរោង២ គឺទំនប់សាយ៉ាបូរី នៅឡាវ និងទំនប់សេសានក្រោម២

| | Lower Sesan 2 Dam | Xayaburi Dam |
|---|---|---|
| Project Profile: គំរោង | សេសានក្រោម២ | សាយ៉ាប៊ូរី |
| Dam capacity,សមត្ថភាពផលិត | 400 MW/100MW | 1,285 MW |
| Height: កំពស់ | 40 meters | 32 meters |
| Length: ប្រវែងនៃទួទំនប់ | 8,000 meters | 820 meters |
| Full Supply Level: កំរិតកំពស់ទឹកពេញទំនប់ | 75 meters,ធៀបនឹងនីវូទឹកសមុទ្រ | 75 meters |
| Cost: តំលៃទំនប់ | ៩៧៧ Million USD លាន | 3.8 billion USD កោដ |
| Type: ប្រភេទទំនប់ | Storage បង្កើតជាអាងស្តុកទឹក | Run-of-the-River លំហូរតាមធម្មជាតិ |
| People Resettled: ចំនួនប្រជាជនត្រូវជំលាសចេញ | About 5,000 people នាក់ | About 2,100 people នាក់ |
| Construction Period: រយៈពេលសាងសង់ | 5 years ឆ្នាំ | 8 years ឆ្នាំ |
| Build-Operate-Transfer (BOT) Agreement: រូបមន្តនៃកិច្ចសន្យា | 45 years(40 years of operation) | 41 years (29 years of operation) |
| Reservoir size: ទំអាងស្តុកទឹក | 33,560 ha ហិចតា | 4,900 ha ហិចតា |
| Revenue for government: ចំណូលពីការបង់ពន្ធចូលថវិកាជាតិ | Estimated at 29.5 million USD in taxes per year (មិនទៀងទាត់អាចចុះជាងនេះ) | Estimated at 676-806 million USD per year |
| Fish species threatened with extinction | 56 | 41 |
| Fish catch impact | 9.3 percent of the Mekong River Basin | 23-100 fish species will no longer be able to migrate (the percent is unclear) |
| Blocked Sediment Flow | 6-8% | Unclear |

| | | |
|---|---|---|
| Earthquake risk: | 5.3 Richter Scale earthquake was in 1973 | 4.7 Richter Scale earthquake was in February 2011 |

## Appendix 6: Welcome Remark in Khmer by Mr. Tek Vannara

**មតិស្វាគមន៍**

លោក តឹក វណ្ណារ៉ា នាយកប្រតិបត្តិ អង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

ថ្លែងក្នុងពិធីផ្សព្វផ្សាយរបាយការណ៍សិក្សាស្រាវជ្រាវដោយសហគមន៍

**ស្តីពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម២**

ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១៤

សណ្ឋាគារអ៊ឹមភើរៀលហ្គាដិន ភ្នំពេញ

សូមគោរព៖

- ឯកឧត្តម តំណាងព្រឹទ្ធសភា និងរដ្ឋសភាជាតិ
- ឯកឧត្តម ទា ជុប អនុរដ្ឋលេខាធិកាក្រសួងបរិស្ថាន
- ឯកឧត្តម តំណាងអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង និងអាជ្ញាធរថ្នាក់ក្រោមជាតិ
- តំណាងបណ្ដាស្ថានទូត និងដៃគូរអភិវឌ្ឍន៍នានា
- លោកពូ អ្នកមីង បងប្អូនតំណាងប្រជាពលរដ្ឋមូលដ្ឋាន
- និងតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលមានវត្តមាននៅទីនេះ!

តាងនាមអោយសម្ព័ន្ធទន្លេកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ខ្ញុំបាទមានមោទនភាពជាខ្លាំង ដែលសមាជិកសហគមន៍ទន្លេសេសាន បុគ្គលិក និងសមាជិកសម្ព័ន្ធទន្លេកម្ពុជាយើងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីធ្វើអោយការសិក្សាស្រាវជ្រាវនេះបានលេចចេញជារូបរាងឡើង និងទទួលបានជោគជ័យដូចដែលលោក-លោកស្រី នឹងបានជ្រាបនៅពេលបន្តិចទៀតនេះ តាមរយៈនៃការធ្វើបទបង្ហាញ របស់តំណាងសហគមន៍មកពីទន្លេសេសាន និងស្រែពក ដែលបានចូលរួមយ៉ាងសកម្មក្នុងការស្រាវជ្រាវ នេះ។

ការសិក្សាស្រាវជ្រាវនេះ ផ្តួចផ្តើមឡើងដោយសហគមន៍ទន្លេសេសាន និងមានការគាំទ្រពីអង្គការសមាជិកសម្ព័ន្ធទន្លេកម្ពុជាដូចជាបណ្ដាញការពារទន្លេសេសាន ស្រែពក សេកុង(3SPN) សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO FORUM) កាលពីដើមឆ្នាំ២០១៤កន្លងទៅក្នុងគោលបំណង ស្វែងរកការពិតពីស្ថានភាពបច្ចុប្បន្នស្តីពីការកាប់ឈើសំអាតផ្ទៃអាងស្តុកទឹក ផែនការតាំងទីលំនៅថ្មី និងផែនការសំណងចំពោះប្រជាពលរដ្ឋដែលនឹងរងផលប៉ះពាល់ ដោយសារការអភិវឌ្ឍទំនប់វារីអគ្គិសនីសេសានក្រោម២។

ម្យ៉ាងទៀត យើងក៏ចង់ដឹងពីលទ្ធភាពនៃការទទួល បានព័ត៌មានរបស់ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងតំបន់គំរោងទំនប់វារីអគ្គិសនីសេសានក្រោម២ និង យន្តការដោះស្រាយគោលការណ៍សំណងរបស់រាជរដ្ឋាភិបាលកម្ពុជា រួមទាំងសាមីក្រុមហ៊ុនដែលទទួលបាន សិទ្ធិវិនិយោគ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី ឮ មីង និងបងប្អូនទាំងអស់ជាទីគោរពរាប់អាន!**

យោងតាមលទ្ធផលនៃការសិក្សាដោយសហគមន៍បង្ហាញថា គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម២ គឺជាគម្រោងខ្នាតធំទី១នៅក្នុងប្រទេសកម្ពុជា ហើយជាគម្រោងមួយពិតប្រាកដមានផែនការច្បាស់លាស់ និងមានដំណើរការសកម្មភាពឆ្ពោះទៅមុខគួរឲ្យកត់សម្គាល់ចាប់តាំងពីឆ្នាំ២០០៧មក។ គម្រោងនេះបានធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានបឋម និងពេញលេញដោយបានបញ្ចប់ក្នុងឆ្នាំ២០០៩ប៉ុន្តែអ្វីដែលជាការកត់សម្គាល់នោះគឺការអនុវត្តសកម្មភាពជាក់ស្តែងនៃទីតាំងគំរោងនៅមានចន្លោះប្រហោងមួយចំនួន ដូចជាការបិទបាំងព័ត៌មានជាមួយសហគមន៍ក្នុងតំបន់អំពីការសំអាតព្រៃផ្ទៃអាងស្តុកទឹក ដែលក្រុមហ៊ុនទទួលបានសិទ្ធិក្នុងការកាប់ឈើ មានការប្រមូលទិញឈើខុសច្បាប់យ៉ាងអនាធិបតេយ្យនៅខាងក្រៅតំបន់អាងស្តុកទឹក មានការសួរនាំច្រើនពីសំណាក់បុគ្គលិកក្រុមហ៊ុន ជាពិសេសអាជ្ញាធរមូលដ្ឋាន (ប៉ូលីសប៉ុស្តិ៍) ពេលដែលក្រុមការងារអង្គការសង្គមស៊ីវិលចុះប្រជុំជាមួយអ្នកភូមិ ដើម្បីប្រមូលព័ត៌មានស្តីពីការវិវត្តន៍របស់គម្រោង។ ផែនការតាំងទីលំនៅថ្មីរបស់ភូមិដែលត្រូវប៉ះពាល់ដោយអាងស្តុកទឹកនៅមិនទាន់ ច្បាស់លាស់ អ្នកភូមិមិនដឹងថាពួកគាត់ត្រូវទៅទីណា សំណូមពរ និងជម្រើសសម្រាប់ទីតាំងថ្មីរបស់ពួកគាត់ ក៏មិនទាន់មានការឆ្លើយតប។ ច្បាប់ស្តីពីគោលការណ៍សំណងនៅមិនទាន់បានផ្សព្វផ្សាយជាសាធារណៈដល់សហគមន៍ក្នុងតំបន់គម្រោង ហើយអ្នកភូមិនៅផ្នែកខាងលើនៃទំបន់ដែលឋិតក្នុងតំបន់នៃអាងស្តុកទឹក គឺនៅមានភាពស្រពិចស្រពិលមិនច្បាស់ថាតើភូមិចំនួនប៉ុន្មានដែលត្រូវធ្វើការផ្លាស់ប្តូរតាំងទីលំនៅថ្មី។ ដូច្នេះតម្លាភាព និងគណនេយ្យភាព ជាពិសេសការទទួលបានព័ត៌មានជាក់លាក់ និងការចូលរួមសម្រេចចិត្តរបស់សហគមន៍រងផលប៉ះពាល់ និងអ្នកពាក់ពន្ធ័ក្នុងការអភិវឌ្ឍគម្រោងនេះ គឺពិតជាមានសារៈសំខាន់ណាស់ដើម្បីសំរេចថាតើគួធ្វើការអភិវឌ្ឍន៍ រឺបញ្ឈប់គំរោងនេះ ដើម្បីធានាចំពោះរការអភិវឌ្ឍប្រកបនិរន្តរភាព។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី ឮ មីង និងបង ប្អូនទាំងអស់ជាទីគោរពរាប់អាន**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងបរិស្ថាន និងស្ថាប័នរាជរដ្ឋាភិបាល រដ្ឋសភាជាតិ ព្រឹទ្ធសភាជាតិ អាជ្ញាធរថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ ដែលតែងតែផ្តល់កិត្តិយសចូលរួមពិភាក្សានៅគ្រប់កម្មវិធីដែលរៀបចំឡើងដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល

ស្តីពីកម្ពុជា និងបង្កលក្ខណៈងាយស្រួលក្នុងការទំនាក់ទំនងក៏ដូចជា បានចូលរួមចំណែកធ្វើអោយធ្វើអោយគ្រប់ការងារទាំងអស់របស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលយើងទទួលបានជោគជ័យរហូតមក។

ថ្ងៃនេះ ជាឱកាសល្អ ដោយក្រុមការងារសហគមន៍ទន្លេសេសាន អង្គការជាសមាជិកសម្ព័ន្ធទន្លេកម្ពុជា និងមន្ត្រីរបស់ NGOF បានបញ្ចប់ជាស្ថាពរនូវការសិក្សាស្រាវជ្រាវនេះ និងបានធ្វើការបោះពុម្ពផ្សាយ រួចរាល់ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ដើម្បីចែកជូនដល់គ្រប់ស្ថាប័នទាំងអស់បានសិក្សាស្វែងយល់បន្ថែម និងអាចចត់ទុកជាឯកសារមូលដ្ឋានដើម្បីធ្វើការពិភាក្សាក្នុងចំណោមអ្នកពាក់ព័ន្ធ និងសិក្សាស្រាវជ្រាវ អំពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីសេសានក្រោម២បន្តទៀត។ ទន្ទឹមនឹងគ្នានេះដែរ ថ្ងៃនេះក៏មានការចូលរួមពី សំណាក់តំណាងប្រជាជនមកពីភូមិនានាដែលរំពឹងថានឹងទទួលរងផលប៉ះពាល់ពីគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២នេះ និងតំណាងអាជ្ញាធរមូលដ្ឋានដូចជាប្រធានភូមិ មេឃុំ ឬតំណាងក្រុមប្រឹក្សា ស្រុកក៏បានចូលរួមផងដែរ ហើយក៏មានការចូលរួមពីប្រសួងបរិស្ថាន ក្រុមហ៊ុនអភិវឌ្ឍន៍គម្រោង និងតំណាងស្ថាន ទូតប្រទេសនានាមួយចំនួនក៏បានចូលរួមស្វែងយល់អំពីរបបគំហើញរបស់របាយការណ៍នេះផងដែរ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី លោកពូ អ្នកមីង និងបងប្អូនទាំងអស់ជាទីគោរពរាប់អាន!**

ដើម្បីកុំអោយខាតពេលវេលា និងដើម្បីទុកឱកាសអោយអ្នកស្រាវជ្រាវមកពីសហគមន៍សេសាន ធ្វើការបកស្រាយអំពីលទ្ធផលដែលបានរកឃើញនៅក្នុងការសិក្សាស្រាវជ្រាវនេះ ក៏ដូចជាទុកឱកាសអោយវាគ្មិនយើងបានលើកឡើងអំពីក្តីកង្វល់ ក៏ដូចជាការយកចិត្តទុកដាក់ដោះស្រាយបញ្ហារបស់ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ខ្ញុំសូមសង្ខេបត្រឹមនេះ។ ខ្ញុំសូមជូនពរអោយការផ្សព្វផ្សាយរបាយការណ៍នាពេលព្រឹកនេះ ប្រព្រឹត្តទៅដោយជោគជ័យ និងសូមប្រកាសអោយប្រើប្រាស់ជាផ្លូវការនូវរបាយការណ៍ស្រាវជ្រាវនេះជាសាធារណៈពីពេលនេះតទៅ។

ជាទីបញ្ចប់នេះ ខ្ញុំសូមជូនពរអោយ ឯកឧត្តម លោកជំទាវ លោក-លោកស្រី តំណាងសហគមន៍ រដ្ឋសភាជាតិ ព្រឹទ្ធសភា ស្ថាប័នរាជរដ្ឋាភិបាល ស្ថានទូត និងបងប្អូនទាំងអស់ សូមអោយមានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ចទាំងអស់។

**សូមអរគុណ!**